អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៩

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីសង្ខេបអំពីដំណើរការសវនាការជំនុំជម្រះក្តីឌុច ក្នុងរយៈពេល៥០ថ្ងៃដំបូង

នាថ្ងៃច័ន្ទ ទី២៧ ខែកក្កដា គឺជាថ្ងៃទី៥០ នៃដំណើរការសវនាការជំនុំជម្រះក្តី កាំង ហ្កេកអ៊ាវ ហៅឌុច ដែលបាន ចាប់ផ្តើមកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។ កាំង ហ្កេកអ៊ាវ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភលើមាត្រាជាក់លាក់មួយចំនួនមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

ក្នុងរយៈពេលកន្លងមក អ្នកជំនាញចំនួនពីរ (២) រូប (លោកណាយ៉ាន់ ចាន់ដា និងលោក ក្រេក អេតធេសាន់) សាក្សីលើអង្គហេតុចំនួនដប់មួយ (១១) រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីរ (៧) រូប បានផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ បន្ថែមលើនេះទៅទៀត សាក្សីលើអង្គហេតុចំនួនប្រាំពីរ (៧) រូប អ្នកជំនាញចំនួនមួយរូប (លោកដេវីត ឆានលើ) និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនម្ភៃ (២០) រូប នឹងត្រូវឡើង មកផ្តល់សក្ខីកម្មរហូតដល់ថ្ងៃទី២៦ ខែសីហាតាមការកំណត់របស់អង្គជំនុំជម្រះសាលាដំបូង។ កាលបរិច្ឆេទ បញ្ចប់នៃដំណើរការសវនាការនៅមិនទាន់កំណត់នៅឡើយនោះទេ។ គិតចាប់ផ្តើមតាំងពីថ្ងៃបើកសវនាការ ដំបូងមក អង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរចំនួន១១ និងសេចក្តី សម្រេចផ្ទាល់មាត់មួយចំនួនទៀតទៅលើបញ្ហានានាទាក់ទងនឹងនីតិវិធីនៃដំណើរការសវនាការជំនុំជម្រះក្តី។

សាធារណៈជននៅតែមានចំណាប់អារម្មណ៍ជាបន្តបន្ទាប់លើដំណើរការសវនាការដែលកំពុងប្រព្រឹត្តទៅនេះ។ តំណាងអ្នកសារព័ត៌មានជាតិនិងអន្តរជាតិសរុបចំនួនបួនរយបួន (៤០៤) នាក់បានចុះឈ្មោះយកព័ត៌មាន

ហើយគិតជាមធ្យមក្នុងមួយថ្ងៃមានតំណាងអ្នកសារព័ត៌មានចំនួន៤៥រូបមកយកព័ត៌មានជាប្រចាំអំពីដំណើរការសវនាការនេះ។ ដំណើរការសវនាការជំនុំជម្រះក្តី ត្រូវបានផ្សាយបន្តផ្ទាល់ជារៀងរាល់ថ្ងៃនៅតាមទូរទស្សន៍ ស៊ីធី អ៊ិន (CTN) សម្រាប់ប្រជាពលរដ្ឋនៅក្នុងប្រទេស និងក្រៅប្រទេស ដែលអាចទស្សនាតាមរយៈអង់តែនខ្សែកាប្លិ៍ និងប្រព័ន្ធផ្កាយរណប និងនៅតាមគេហទំព័ររបស់វិទ្យុអាស៊ីសេរី។ ស្ថានីយទូរទស្សន៍អប្សរា ក៏បានចាក់ផ្សាយមិនផ្ទាល់អំពីដំណើរសវនាការនេះជាប្រចាំថ្ងៃផងដែរ។

មកដល់ថ្ងៃកំណត់ទី៥០ ដំបូងនេះ មានប្រជាពលរដ្ឋចំនួន មួយម៉ឺនពីរពាន់ប្រាំបួនរយកៅសិបប្រាំមួយ(១២៩៩៦) នាក់ បានចូលរួមក្នុងដំណើរការសវនាការ ដោយគិតជាមធ្យមមានអ្នកទស្សនា ២៥៩ នាក់ក្នុងមួយថ្ងៃ។

**ខែមីនា (សវនាការថ្ងៃទី១ និងទី២)**

ការអានដីការដំណោះស្រាយ។ ការព្រមព្រៀងទៅលើអង្គហេតុក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ក្នុងពីរថ្ងៃដំបូងនៃសវនាការនេះគ្មានសាក្សីឆ្លើយបំភ្លឺនោះទេ

**ខែមេសា (សវនាការថ្ងៃទី៣ ដល់ទី១៥)**

ជនជាប់ចោទត្រូវបានសួរអំពីអង្គហេតុនានាទាក់ទងនឹងមន្ទីរ ម១៣ និងការបង្កើតមន្ទីរ ស២១។ សាក្សីបួននាក់ដំបូងរួមមានលោកហ្វ្រង់ស្វ័រ ប៊ីហ្សូ លោកអ៊ុំច សន លោកចាន់ វឿន និងលោកចាន់ ខន បានមកផ្តល់សក្ខីកម្ម។

**ខែឧសភា (សវនាការថ្ងៃទី១៦ ដល់ទី២៣)**

ជនជាប់ចោទត្រូវបានសួរអំពីអង្គហេតុនានាទាក់ទងនឹងជម្លោះប្រដាប់អាវុធ។ ការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១។ អ្នកជំនាញចំនួនពីររូប គឺលោក ណាយ៉ាន់ ចាន់ដា និងលោកក្រេក អេតឆេសាន់ បានមកផ្តល់សក្ខីកម្ម។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**ខែមិថុនា (សវនាការថ្ងៃទី២៤ ដល់ទី៣៦)**

ជនជាប់ចោទត្រូវបានសួរអំពីអង្គហេតុនានាទាក់ទងនឹងជម្លោះប្រដាប់អាវុធ ការអនុវត្តន៍គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរស២១ ស២៤ (ព្រៃស) និងជើងឯក។ សាក្សីចំនួនមួយរូបដែលជាអ្នករស់រានមានជីវិតពីមន្ទីរស២១ គឺលោក វ៉ាន់ ណាត បានមកផ្តល់សក្ខីកម្ម។

**ខែកក្កដា (សវនាការថ្ងៃទី៣៧ ដល់ទី៥០)**

សាក្សីលើអង្គហេតុចំនួន៦ រូប គឺលោកនង ចាន់ផល លោកម៉ម ណៃ លោកហ៊ិម ហ៊ុយ លោកប្រាក់ ខន និងលោកគោក ស្រស់ និងលោកសួស ធី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំពីររូប រួមមានលោកជុំ ម៉ី លោកប៊ូ ម៉េង  លោកលី ហ៊ រ លោកឡាយ ចាន់ លោកភោគ ខន លោកស្រីជីន ម៉េត និងលោកស្រីណាំ ម៉ុន បានផ្តល់សក្ខីកម្មទាក់ទងប្រតិបត្តិការនៅមន្ទីរស២១ និងជើងឯក។

ប្រតិចារិកស្តីពីដំណើរការសវនាការប្រចាំថ្ងៃ និងឯកសារផ្សេងៗដែលបានបង្ហាញក្នុងសាលសវនាការអាចស្វែងរកបានតាមរយៈ អាសយដ្ឋាននៃគេហទំព័រ៖
http://www.eccc.gov.kh/khmer/caseInfo001.aspx

រូបថតស្តីពីដំណើរការសវនាការប្រចាំថ្ងៃ អាចស្វែងរកបានតាមរយៈ អាសយដ្ឋាននៃគេហទំព័រ៖
http://www.flickr.com/photos/krtribunal/

សម្រាប់រូបថតទាំងនេះ  អ្នកសារព័ត៌មានទាំងអស់អាចប្រើប្រាស់បានតាមសេចក្តីត្រូវការ  ប៉ុន្តែគួរតែបញ្ជាក់ថារូបថតទាំងនេះផ្តល់ដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង**

លោករាជ សម្បត្តិ
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទចល័តលេខ +855 (0) 12 488 156
សារអេឡិចត្រូនិច reach.sambath@eccc.gov.kh

លោកឌឹម សុវណ្ណារុំ
មន្ត្រីទទួលបន្ទុកការងារព័ត៌មាន
ទូរស័ព្ទចល័តលេខ +855 (0) 12 488 094
សារអេឡិចត្រូនិច dim.sovannarom@eccc.gov.kh

លោកឡាស អូលសិន
មន្ត្រីទទួលផ្នែកទំនាក់ទំនងផ្លូវច្បាប់
ទូរស័ព្ទចល័តលេខ +855 (0) 12 488 023
ទូរស័ព្ទលេខ +855 (0) 23 219 814 លេខបន្ត 6169
សារអេឡិចត្រូនិច olsen@un.org